# អនុក្រឹត្យលេខ ១៦/អនក្រ.បក

## ស្តីពីការលុបប្រកាសរបស់ក្រសួងមហាផ្ទៃ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/៩៤/០៦ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.តត ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការ
- យោងប្រកាសលេខ ១០១៧/ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៦៥/សជណ/ផក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងលិខិតលេខ ៨១/មស/ក្រខ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៨ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងសំណើសុំរបស់លោក គង ស៊ាន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៩

## សំរេច

**មាត្រា ១ .-** កែតម្រូវឆ្នាំកំណើតរបស់លោក គង ស៊ាន ពីឆ្នាំ ១៩៥៥ មកជាឆ្នាំ ១៩៥៨ និងនិរាករណ៍ប្រកាសលេខ ១០១៧ ប្រក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការដាក់មន្ត្រីរាជការអោយចូលនិវត្តន៍របស់ក្រសួងមហាផ្ទៃ ចំពោះតែលោក គង ស៊ាន ម្នាក់ប៉ុណ្ណោះ ។ ចំណែកឯលោក ខណ្ឌ គីរីរត្ន ដែលមានឈ្មោះក្នុងប្រកាសនេះដែរនោះនៅមានអនុភាពដដែល ។

**មាត្រា ២ .-** ត្រូវបានប្រគល់ភារកិច្ចជូនលោក គង ស៊ាន អោយទទួលបន្ទុកតាមដានសភាពការណ៍នៅរាជធានីភ្នំពេញ ។

**មាត្រា ៣ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

មាត្រា ៤.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១៧/អនក្រ.បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ

## របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០

www.pheakdeylaw.com